MOSALVY

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១០០ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការព្យួរការសំរាកប្រចាំសប្តាហ៍

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបាន ក្នុងករណីដូចមានចែងក្នុងមាត្រា ១៥១ នៃច្បាប់ស្តីពីការងារ ។

**ប្រការ២.-** នៅក្នុងសហគ្រាស គ្រឹះស្ថានខ្លះ និយោជកអាចកាត់បន្ថយការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតចំនួន ២ថ្ងៃក្នុងមួយខែ ដើម្បីទូទាត់ថ្ងៃធ្វើការមិនកើតកន្លងទៅ ដែលបណ្តាលមកពីអាកាសធាតុមិនល្អ។ សហគ្រាស គ្រឹះស្ថានប្រភេទនេះ មានដូចតទៅ:-

-សហគ្រាស គ្រឹះស្ថានបំរើការងារសាធារណៈដូចជា ការងារបោសសំអាត ឬប្រមូលសំរាមនៅតាម

ផ្ទះ ទីលានសាធារណៈ ការងារជួសជុល ធ្វើផ្ទះ ឬលូទឹក

-សហគ្រាស គ្រឹះស្ថានបំរើការងារជួសជុល ឬតភ្ជាប់ទឹក ឬបំពង់ឧស្ម័ន ជួសជុល ឬប្រក់ដំបូលផ្ទះ ឬអគារ

-សហគ្រាស គ្រឹះស្ថានតំរែតំរង់ ចំពោះការងារដែលប្រព្រឹត្តទៅនៅផ្នែកខាងក្រៅនៃអគារ

-សហគ្រាស គ្រឹះស្ថានឡជដ្ឋ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថានកាយយករ៉ែ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថានដឹកជញ្ជូនតាមផ្លូវទឹក

-ភោជនីយដ្ឋាន និងកន្លែងលក់ដូរដែលប្រព្រឹត្តទៅនៅកណ្តាលវាល

-សហគ្រាស គ្រឹះស្ថាន បេះ ឬប្រមូលផ្លែឈើ ឬបន្លែ

-សហគ្រាស គ្រឹះស្ថាន ចិញ្ចឹមសត្វសន្ទានខ្សែ ខ្ចៅ ឬត្រី

-សហគ្រាស គ្រឹះស្ថាន ផលិតទឹកត្រី ឬរំពេច

-សហគ្រាស គ្រឹះស្ថាន ធ្វើប្រកកំប៉ុងនូវផ្លែឈើ បន្លែ ឬត្រី

-សហគ្រាស គ្រឹះស្ថាន លើកដាក់ផលិតផល ឬវត្ថុធាតុដែលឆាប់ខូច

-សហគ្រាស គ្រឹះស្ថានកសិកម្ម និងនេសាទ ។

ការធ្វើការសងនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ចំពោះប្រភេទសហគ្រាស គ្រឹះស្ថាន ដូចបានរៀបរាប់ខាងលើ ត្រូវអនុវត្តក្នុងខែបន្ទាប់ពីថ្ងៃធ្វើការមិនកើតដោយអាកាសធាតុមិនល្អ ។ ករណីត្រូវធ្វើការសងពីរថ្ងៃ ថ្ងៃទាំងពីរនេះមិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដទៃទៀតក៏អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបានដែរ ។ ការព្យួរនេះ បើបានចំនួន ២ថ្ងៃក្នុងមួយខែ មិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ពីរដែលជាប់គ្នាឡើយ ។

**ប្រការ៤.-** នៅមុនពេលដាក់អោយកម្មករនិយោជិតធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ខាងលើ និយោជកត្រូវស្នើសុំសេចក្តីអនុញ្ញាតពីអធិការការងារ " ដោយបញ្ជាក់ពីមូលហេតុនៃការព្យួរការឈប់សំរាកប្រចាំសប្តាហ៍នេះ កាលបរិច្ឆេទ និងថិរវេលានៃការព្យួរ ចំនួនកម្មករនិយោជិតដែលមិនបានឈប់សំរាក ព្រមទាំងបែបបទនៃការឈប់សំរាកសងដោយទូទាត់វិញក្នុងរយៈពេល ៣០ថ្ងៃ " ។ អធិការការងារត្រូវជូនដំណឹងដល់ និយោជក ដែលសុំការអនុញ្ញាតនោះ អំពីការសំរេចរបស់ខ្លួនក្នុងរយៈពេល ៤ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ បើមិនដូច្នេះទេពាក្យសុំការអនុញ្ញាត និងត្រូវចាត់ទុកថាបានយល់ព្រមហើយ ។

**ប្រការ៥.-** កម្មករ និយោជិតដែលធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដងនៃប្រាក់

ឈ្នួលថ្ងៃធ្វើការធម្មតា ។

**<u>ប្រការ៦</u>.~** ក្នុងករណីប្រធានស័ក្តិ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិត ដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអធិការការងារឡើយ ។

**<u>ប្រការ៧</u>.~** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៩១ សកអ. ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ និងលេខ២០៩ សកអ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**<u>ប្រការ៨</u>.~** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

-សមាគមនិយោជក
-សហព័ន្ធសហជីព

" ដើម្បីជ្រាប "

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ